# អរិយធម៌រ៉ូម

ប្រវត្តិសាស្ត្រនៃអរិយធម៌រ៉ូមបុរាណ គឺទាក់ទងជាមួយនឹងការវិវត្តន៍ប្រវត្តិសាស្ត្រនយោបាយ វប្បធម៌ ដែលបានបង្ហាញពីការប្រែប្រួលរបបនយោបាយក្នុងសង្គមរបស់ខ្លួនចាប់តាំងពីដើមស.វ.ទី១មុនគ.ស.មក ។

មុននឹងក្លាយជាអាណាចក្ររ៉ូមាំង រ៉ូមដែលជាទីក្រុងតូចមួយនៅតាមបណ្ដោយទន្លេទិប (Tibre) ស្ថិតនៅកណ្ដាលនៃប្រទេសអ៊ីតាលី។ នៅដើមស.វ.ទី១ រ៉ូមចាប់ផ្ដើមពង្រីកទឹកដីវិសាលភាពរបស់ខ្លួនរហូតដល់ឈូងសមុទ្រពៃក្ស ទាំងនយោបាយ កងទ័ព និងទំនៀមទម្លាប់របស់ខ្លួន ដែលក្រោយមកបានក្លាយជាអត្តសញ្ញាណវប្បធម៌លោកខាងលិច[១] (រូបលេខ១)។

នៅក្នុងប្រវត្តិសាស្ត្ររ៉ូមបុរាណអ្នកស្រាវជ្រាវ បានបែងចែកចេញជាបីសម័យកាលធំៗ ក្នុងនោះមានដូចជា សម័យរាជានិយម ( Royal ) សម័យសាធារណ:( Republic) និងសម័យអធិរាជរ៉ូម ( Imperial )។ ក្នុងអំឡុងពេលដែលរ៉ូមបុរាណកាន់របបរាជានិយម គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ដេចចំនួន២អង្គ។ តាមរយ:រឿងព្រេង ស្ដេចដំបូងគឺមានឈ្មោះថា Romulus និងបន្ទាប់មកទៀតគឺ ស្ដេច Remus ដែលជាប្អូនបង្កើត (រូបលេខ២)។[២] តាមរយ:រឿងព្រេងនោះដែរ ទីក្រុងរ៉ូមបុរាណត្រូវបានកសាងដោយស្ដេច Romulus និង Remus នៅឆ្នាំ ៧៥៣មុនគ.ស. ដែលអ្នកស្រាវជ្រាវបានប៉ាន់ស្មានថា ទីក្រុងរ៉ូមពេលនោះមានប្រជាជនរស់នៅច្រើនជាងប្រជាជនក្នុងតំបន់អ៊ឺរ៉ុបនាទ.ស.ទី៩០។[៣] នៅឆ្នាំ ៥០៩ មុនគ.ស. រ៉ូមបុរាណបានផ្លាស់ប្ដូរមកកាន់របបសាធារណ: ដោយបានធ្វើការបណ្ដេញស្ដេចឱ្យចុះចេញពីបល្ល័ង្គ ដោយជំនួសមកវិញនូវការបោះឆ្នោត ដោយជ្រើសរើសអ្នកដឹកនាំថ្មីចំនួនពីរនាក់ដែលហៅថា កុងសុល (Consul)។[៤] មេដឹកនាំ ឬកុងសុលដែលល្បីឈ្មោះជាង

---

[១] www.Nationalgeographic.com: ancient Rome

[២] *Ibid*

[៣] Mary Beard , 2015, p.17

[៤] Frédéric Hurlet ,2018, p.371-397

អត្ថបទដោយ៖ អេង តុលា

គេនោះ មានឈ្មោះ ថា Jules Cesar(៤៩-៤៤មុនគ.ស)(រូបលេខ២៣)។ បន្ទាប់មកទៀតគឺ សម័យកាលអធិរាជរ៉ូមាំង ដែលរ៉ូមបុរាណចាប់ផ្តើមធ្វើសង្គ្រាមរៀតទឹកដី ហើយបាន ក្លាយជាអាណាចក្ររ៉ូមាំងដ៏រុងរឿង ក្រោមការដឹកនាំដោយមេដឹកនាំឈ្មោះ Octave ដែល ក្រោយមកក្លាយជាអធិរាជ Auguste[៥] (២៧មុនគ.ស. ដល់១៤គ.ស.) (រូបលេខ២៤) និងអធិរាជ មួយព្រះអង្គទៀតមានឈ្មោះ Nero (៥៤មុនគ.ស. ដល់៦៨គ.ស.)(រូបលេខ២៥) ដែលបាន ពង្រីកទឹកដី អាណាចក្ររ៉ូមឱ្យកាន់តែធំជាងមុន នៅតំបន់សមុទ្រមីឌីទែរ៉ាណេ។ នៅ សម័យនោះរ៉ូម ចាប់ផ្តើមធ្វើសង្គ្រាមដណ្តើមទឹកដីលើប្រទេសជិតខាងខ្លួនដែលមានដូច ជា ក្រិច អេហ៊ីប និង កាតាច (Carthage ) សព្វថ្ងៃជាប្រទេសទុយនេស៊ី ។

ភាសាឡាតាំងត្រូវបានគេដឹងថា ជាភាសាផ្លូវការរបស់រ៉ូមបុរាណ ហើយស្ថិតនៅក្នុង អំបូរភាសា ឥណ្ឌូអ៊ឺរ៉ុប ដែលជាមូលដ្ឋានគ្រឹះនៃភាសាមួយចំនួនបណ្តាប្រទេសក្នុងតំបន់អ៊ឺរ៉ុប ដូចជា បារាំង អេស្ប៉ាញ ព័រទុយកាល់ និងរ៉ូម៉ានីជាដើម។[៦] ចំពោះសិល្បៈ ស្ថាបត្យកម្ម រ៉ូមាំងត្រូវបានគេដឹងថា ទទួលឥទ្ធិពលពីអរិយធម៌ក្រិចបុរាណ។ សំណង់ស្ថាបត្យកម្មក្រិច បុរាណ ជាពិសេសសំណង់សសរដែលល្បីលាញត្រូវបានពួករ៉ូមាំងយកមកប្រើប្រាស់ និង ការវិវត្តន៍ក្នុងសិល្បៈរបស់ខ្លួន ហើយហៅថា Pantheon និង Colisee (រូបលេខ២៦-៧)។ អំឡុង ពេលនៃការគ្រប់គ្រង អាណាចក្ររ៉ូមាំងមានការរីកចម្រើនយ៉ាងខ្លាំង។ រាល់សំណង់ហេដ្ឋា រចនាសម្ព័ន្ធដូចជា សំណង់ជាពសាស្ត្រ ជាពិសេសសំណង់ស្ពានទឹក អាងទឹកសាធារណៈ ព្រះរាជវាំង សំណង់ Forums សំណង់ Colosseum ជាដើម។ នៅប្រមាណស.វ.ទី៤នៃគ.ស អាណាចក្ររ៉ូមាំងចាប់ផ្តើមចុះខ្សោយ និងដួលរលំដែលបណ្តាលមកពីកត្តាផ្សេងៗ។ កត្តា ចម្បងនោះគឺ អំពីផុករលួយក្នុងនយោបាយ សេដ្ឋកិច្ចធ្លាក់ចុះ ការមានសង្គ្រាមផ្ទៃក្នុង និង ការឈ្លានពានពីអាណាចក្រជិតខាងដែលជាដើមចមនៃការដួលរលំអាណាចក្ររ៉ូមាំង។

---

[៥] https://www.geo.fr : comment-octave-est-devenu-auguste-premier-empereur-de-rome

[៦] www.history.com: ancient Rome

អត្ថបទដោយ៖ អេង តុលា

ពល់ទន្និន័យទាំងអស់ដែលបានបង្ហាញខាងលើនេះ អាចបង្ហាញឱ្យយើងដឹងបានថា អរិយធម៌រ៉ូមត្រូវបានគេស្គាល់ថា ជាអរិយធម៌ ដែលមានឥទ្ធិពលខ្លាំងលំដាប់ទី២បន្ទាប់ អរិយធម៌ក្រិចក្នុងប្រវត្តិសាស្ត្រតំបន់អ៊ឺរ៉ុប។ ការដែលសម្គាល់ថា បែបនេះ គឺតាមរយៈវិសាលភាព នៃការគ្រប់គ្រងទឹកដីស្ទើរទាំងស្រុងនៃតំបន់អ៊ឺរ៉ុប និងសំណង់ស្ថាបត្យកម្មដែលបានបន្សល់ទុកជាច្រើននៅក្នុងបណ្តាប្រទេសក្នុងតំបន់អ៊ឺរ៉ុប ជាពិសេសសំណង់ស្ថាបត្យកម្មបុរាណស្ថិតក្នុងរាជធានី រ៉ូមផ្ទាល់។




រូបលេខ១៖ ផែនទីរ៉ូមាំងបុរាណ

ប្រភព៖ Britannica

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៖ ចម្លាក់ទាក់ទងនឹងរឿងព្រេង Romulus និង Remus

ប្រភព៖ Britannica



រូបលេខ៣៖ ចម្លាក់ នៃ Jules Cesar

ប្រភព៖ Britannica

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៤៖ ចម្លាក់ នៃអធិរាជAuguste

ប្រភព៖ Britannica



រូបលេខ២៥៖ ចម្លាក់ នៃអធិរាជNero

ប្រភព៖ Britannica

អត្ថបទដោយ៖ អេង តុលា




រូបលេខ៦៖ ព្រះវិហារ Patheon of Rome
ប្រភព៖ Britannica



រូបលេខ៧៖ សំណង់Colosseum

អត្ថបទដោយ៖ អេង តុលា



រូបលេខ៨៖ សំណង់ស្ពានទឹក សម័យរ៉ូមាំង

ប្រភព៖ Worldhistory



រូបលេខ៩៖ Palatine Hill ដែលស្ថិតនៅក្នុងទីក្រុងរ៉ូម

អត្ថបទដោយ៖ អេង តុលា



រូបលេខ១០៖ Palatine Hill ដែលស្ថិតនៅក្នុងទីក្រុងរ៉ូម



រូបលេខ១១៖ កន្លែងងូតទឹកសាធារណៈសម័យរ៉ូមាំង

ប្រភព៖ Pixabay

អត្ថបទដោយ៖ អេង តុលា

# ឯកសារយោង

Mary Beard ,

2015 History of ancient Rome

Frédéric Hurlet

2018 La Rome antique

Website

www.Nationalgeographic.com: ancient Rome

https://www.geo.fr : comment-octave-est-devenu-auguste-premier-empereur-de-rome

www.history.com: ancient Rome

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION